ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខ : ០៤៨/១១/រ.ដ.អអ.ជ.ប.គ.ញ

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែឧសភា ឆ្នាំ ២០១១

របាយការណ៍

# ស្តីពី

# លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែមីនា ឆ្នាំ២០១១
# និង ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែមេសា ឆ្នាំ២០១១

(០១/០៣/២០១១-៣១/០៣/២០១១)

ខែមីនាឆ្នាំ២០១១ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តតាមយុទ្ធសាស្ត្រពហុវិស័យទាំង៥ ដែលបានដាក់ចេញកាលពីខែកុម្ភៈកន្លងទៅ សំដៅរួមចំណែករក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម ស្របតាមកម្មវិធីនយោបាយជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤នៃរដ្ឋសភា ។ សកម្មភាពនិងលទ្ធផលការងារដែលអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានខិតខំអនុវត្តនៅក្នុងខែមីនានេះ មានដូចតទៅ :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

ខែមីនាឆ្នាំ២០១១នេះ ការចរាចរគ្រឿងញៀនប្រភេទ មេតំហ្វេតាមីនគ្រាប់(WY) និង មេតំហ្វេតាមីនទឹកកក(ICE) តាមផ្លូវគោកពីតំបន់ព្រំដែនភាគឦសាននៅតែបន្តកើតមានឡើង ។ នៅពេលគ្រឿងញៀនទាំងនោះបាននាំឆ្លងផុតតំបន់ព្រំដែនចូលមកក្នុងប្រទេស ពួកឈ្មួញក្នុងស្រុកដែលជាខ្សែបណ្តាញបានធ្វើការចរាចរជួញដូរចែកចាយបន្តទៅបណ្តាខេត្តនានា ។ មន្ត្រីអនុវត្តច្បាប់គ្រប់សមាសភាព រួមមាន អគ្គស្នងការដ្ឋាននគរបាលជាតិ (មន្ទីរប្រឆាំងគ្រឿងញៀន, នាយកដ្ឋានសន្តិសុខផ្ទៃក្នុង) និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្តចំនួន១២គឺ រាជធានីភ្នំពេញ, ខេត្តបន្ទាយមានជ័យ, ខេត្តបាត់ដំបង, ខេត្តកោះកុង, ខេត្តព្រះសីហនុ, ខេត្តប៉ៃលិន, ខេត្តស្ទឹងត្រែង, ខេត្តកណ្តាល, ខេត្តកំពង់ស្ពឺ, ខេត្តកំពង់ចាម, ខេត្តស្វាយរៀង, ខេត្តពោធិ៍សាត់, កងរាជអាវុធហត្ថ និងមន្ត្រីចម្រុះដែលប្រចាំការនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ បានសហការរកឃើញនិងបង្ក្រាបជាបន្តបន្ទាប់ ។

លទ្ធផលនៃការបង្ក្រាបបានបង្ហាញថា បទល្មើសផលិតគ្រឿងញៀនចំនួន០២ករណី ១ករណីមានទីតាំងស្ថិតនៅក្នុងខណ្ឌមានជ័យ និង១ករណីជាការផលិតចល័តនៅលើរថយន្ត និងមានការដឹកជញ្ជូនគ្រឿងញៀនជាលក្ខណៈអន្តរជាតិ១ករណី ត្រូវបានសមត្ថកិច្ចចម្រុះនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញរកឃើញនៅថ្ងៃទី២១ខែមីនាឆ្នាំ២០១១ ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### *-ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់លើកកម្ពស់វិធានការពហុវិស័យទាំង៥ ក្នុងការត្រួតពិនិត្យគ្រឿងញៀន ជាអាទិ៍ :

-បានជួបពិភាក្សាការងារជាមួយឯកអគ្គរដ្ឋទូតប្រទេសសឹង្ហបុរី ( ថ្ងៃទី០២-៣-២០១១) ។

-បានអញ្ជើញជាអធិបតីនៅក្នុងកិច្ចប្រជុំបូកសរុបលទ្ធផល និងដកពិសោធន៍លើការអនុវត្តន៍ផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១០ របស់ខេត្តបន្ទាយមានជ័យ(២៨-២៩ ខែមីនា ឆ្នាំ២០១១) ។

-បានណែនាំឱ្យរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១០ និងលើកទិសដៅការងារឆ្នាំ ២០១១ នៅខេត្តជាប់ព្រំដែនប្រទេសឡាវ( ០៦-០៧ មេសា ២០១១) ។

-បានអនុញ្ញាតជាគោលការណ៍ ឱ្យគណៈប្រតិភូអន្តរក្រសួងទៅធ្វើទស្សនកិច្ចសិក្សា លើការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ( ១៤-១៨ មីនា ២០១១) ។

-បានណែនាំឱ្យរៀបចំពិធីប្រកាសតែងតាំងមុខតំណែង អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន អជបគញ ថ្ងៃទី១១ ខែមីនាឆ្នាំ២០១១ ក្រោមអធិបតីភាពឯកឧត្តម **កៅ ខុនដារ៉ា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

-បានអនុញ្ញាតជាគោលការណ៍ ឱ្យដាក់បញ្ចូលខ្លឹមសារស្មារតីដែលបានឯកភាពគ្នានៅក្នុងកិច្ចប្រជុំទ្វេភាគី កម្ពុជា-វៀតណាម លើកទី១០ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន និងគំរោងស្នើសុំជំនួយកសាងមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ទៅក្នុងគំរោងនៃកិច្ចសហប្រតិបត្តិការអនាគត សំរាប់ត្រៀមកិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា-វៀតណាម លើកទី១២ នៅខែមេសាឆ្នាំ២០១១ ។

-បានអនុញ្ញាតឱ្យលោក Francoise Barre-Sinoussi សហប្រធាននៃគណៈកម្មការជាន់ខ្ពស់អង្គការ UNAIDS ចូលជួបសវនាការនិងសំដែងការគួរសម ។

-បានណែនាំឱ្យចូលរួមសិក្ខាសាលាអន្តរក្រសួង ដើម្បីពិភាក្សានិងផ្តល់ការឯកភាពលើ សំណុំសូចនាករថ្មី សំរាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃពាក់កណ្តាលអាណត្តិឆ្នាំ២០១១នៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ( ផយអជ) បច្ចុប្បន្នកម្ម ២០០៩-២០១៣ ដែលក្រសួង-ស្ថាប័នពាក់ពន្ធ័បានស្នើឡើង ។

-បានណែនាំ អគ្គលេខាធិការដ្ឋាន អជបគញ ឱ្យត្រៀមលក្ខណៈរៀបចំសន្និបាតបូកសរុបការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១០ និងលើកទិសដៅការងារឆ្នាំ២០១១ ។

-បានណែនាំ អគ្គលេខាធិការដ្ឋាន អជបគញ ឱ្យសហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ដើម្បីធ្វើស្ថិតិ ទិន្នន័យបទល្មើសគ្រឿងញៀនឱ្យបានជាក់លាក់ ។

**១.ការកាត់បន្ថយតម្រូវការគ្រឿងញៀន**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដឹកនាំនិងសហការសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ធ្វើការផ្សព្វផ្សាយអប់រំ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីច្បាប់, គ្រោះថ្នាក់នៃគ្រឿងញៀន និងការរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ តាមរយៈសកម្មភាព ជាអាទិ៍ :

-បានផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍CTN ដោយអគ្គលេខាធិការដ្ឋាន អជបគញ ស្តីពីអត្តសញ្ញាណគ្រឿងញៀន និង ឥទ្ធិពលនៃគ្រឿងញៀន នាថ្ងៃទី៣០ខែមីនាឆ្នាំ២០១១ ។

-បានផ្តល់ឯកសារសម្រាប់ផ្សព្វផ្សាយអប់រំដល់ខេត្តកំពង់ចាម ដើម្បីអនុវត្តកម្មវិធីលើកកម្ពស់ការយល់ដឹងពីច្បាប់ និង គ្រោះថ្នាក់នៃគ្រឿងញៀនដល់មន្ត្រីរាជការ មន្ត្រីអនុវត្តច្បាប់ សិស្សានុសិស្ស ប្រជាពលរដ្ឋ បានយល់ដឹងទូលំទូលាយ ។

-បានផ្តល់ឯកសារស្តីពីផលប៉ះពាល់នៃគ្រឿងញៀន ដល់និស្សិតនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ។

-បានផ្តល់ឯកសារជូន សមាគមសង្គ្រោះជនរងគ្រោះដោយគ្រឿងញៀនកម្ពុជា សម្រាប់អប់រំពន្យល់ណែនាំដល់ក្រុមជនរងគ្រោះដោយសារគ្រឿងញៀន ដែលកំពុងសម្រាកព្យាបាលបន្សាបជាតិញៀននៅក្នុងមណ្ឌល ។

សកម្មភាពការងារទាំងអស់ខាងលើ រួមទាំងការងារផ្សព្វផ្សាយប្រចាំខែរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្តនានា មានមន្ត្រីរាជការ និងប្រជាពលរដ្ឋចូលរួម សរុប **១៧.៥១៨** នាក់ ។

**២.ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន**

ខែមីនាឆ្នាំ២០១១នេះ អគ្គស្នងការដ្ឋាននគរបាលជាតិ, កងរាជអាវុធហត្ថជាតិ និងមន្ត្រីចម្រុះប្រចាំការនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ បានបើកកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម :

-បង្ក្រាបបទល្មើសគ្រឿងញៀនបាន **១១៣ ករណី**, ឃាត់ជនសង្ស័យ **២៩៦ នាក់** (ប្រុស២២៩នាក់ ស្រី៦៧នាក់) ក្នុងនោះ ជនជាតិខ្មែរ ២៧៦ នាក់(ប្រុស២១៨នាក់ ស្រី៥៨នាក់), វៀតណាម ១៤នាក់(ប្រុស៧ នាក់ ស្រី៧នាក់), នីហ្សេរីយ៉ា ៤នាក់(ប្រុស៣នាក់ ស្រី១នាក់), អាមេរិក ១នាក់(ប្រុស), ហ្វីលីពីន ១នាក់(ស្រី) ។

**វត្ថុតាងចាប់យក** រួមមាន : មេតំហ្វេតាមីនWY ១១៩.៧៨៤ គ្រាប់, មេតំហ្វេតាមីនICE ៦.៥៨៤,៣២ ក្រាម, កញ្ឆាក្រៀម ២៧៧,៦២ ក្រាម និង ២កញ្ចប់, ហេរ៉ូអ៊ីន ៤,២៦ ក្រាម, អ៊ិចស្តាស៊ី ៤ គ្រាប់, ម្សៅពណ៌ស 0,៤0 ក្រាម, Pseudo-Ephedrine ៦.២១០ ក្រាម, សារធាតុផ្សំគ្រឿងញៀន ៤មុខ=២.៦៨២ ដប និង ៥បាវ, ជញ្ជីង១, កាំភ្លើងខ្លី១, រថយន្ត ១២ គ្រឿង, ម៉ូតូ ២១គ្រឿង, ទូរស័ព្ទដៃ៨, កុំព្យូទ័រយួរដៃ២, IPAD ២គ្រឿង, ម៉ាស៊ីនថតរូប ២គ្រឿង, និងឧបករណ៍ផលិតនិងប្រើប្រាស់គ្រឿងញៀនមួយចំនួន ។

ដោយឡែក សារធាតុគីមីផ្សំដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលដោយ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) ប្រចាំខែមីនាឆ្នាំ២០១១ សរុបចំនួន 7.274.252,2 គីឡូក្រាម, 5.140 លីត្រ និង 20 អំពូល ។

*ពាក់ព័ន្ធនឹងការងារអនុវត្តច្បាប់ នៅក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលនិងដកពិសោធន៍លើការអនុវត្តន៍ផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១០ របស់ខេត្តបន្ទាយមានជ័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អជបគញ បានផ្តល់នូវអនុសាសន៍ណែនាំដូចតទៅ :

- ក្រសួងយុត្តិធម៌ ត្រូវតាមដានការចាប់បញ្ជូនខ្លួនជនល្មើស ដោយស្ថាប័នអនុវត្តច្បាប់ទៅតុលាការ, ការកាត់ទោសដោយសាលាដំបូងរាជធានី-ខេត្ត និងត្រូវតាមដានអំពីការរឹបអូសទ្រព្យដែលបានមកពីជំនួញគ្រឿងញៀនខុសច្បាប់ ហើយត្រូវរាយការណ៍មកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។ ការងារនេះ ក្រសួងយុត្តិធម៌ត្រូវមានយន្តការមួយសម្រាប់តាមដាន និងធ្វើជាសេនាធិការឱ្យអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- គ្រប់រាជធានី-ខេត្ត ជាពិសេស ខេត្តបន្ទាយមានជ័យ ត្រូវបន្តយកចិត្តទុកដាក់ដឹកនាំលើការងារអនុវត្តច្បាប់ ឱ្យដូចភ្លៀងរលឹម ដើម្បីប្រឆាំងនឹងបញ្ហាគ្រឿងញៀន ដែលកើតមាននៅក្នុងភូមិសាស្ត្ររបស់ខេត្ត ។ ក្នុងនោះ ចំពោះពួកឈ្មួញត្រូវអនុវត្តវិធានការបង្ក្រាបឱ្យបានម៉ឺងម៉ាត់ ហើយចំពោះអ្នកស្ថិតនៅក្រោមឥទ្ធិពលគ្រឿងញៀន ត្រូវចលនាឱ្យគេចូលខ្លួនមកទទួលយកសេវាថែទាំព្យាបាល ។
- គ្រប់ខេត្តនៅតាមព្រំដែន ជាពិសេស ខេត្តបន្ទាយមានជ័យ ត្រូវពង្រឹងការទំនាក់ទំនងជាមួយខេត្ត ស្រុក ឃុំ ភូមិ

ដែលជាប់ព្រំដែនជាមួយប្រទេសថៃ ក្នុងការទប់ស្កាត់ការជួញដូរគ្រឿងញៀន ឬព័ត៌មានផ្សេងៗ ដែលបានផ្តល់ឱ្យគ្នាទៅវិញទៅមក ជាពិសេស លើការត្រួតពិនិត្យសារធាតុគីមីផ្សំ ។ ក្នុងនោះ ត្រូវយកចិត្តទុកដាក់ពង្រឹងសមត្ថភាព ពង្រឹងការស្មោះត្រង់ និងគុណធម៌មិនល់មន្ត្រីអនុវត្តច្បាប់ គ្រប់សមាសភាព និងគ្រប់លំដាប់ថ្នាក់ ។

### ៣.ការព្យាបាល ស្តារនីតិសម្បទា និង ការកាត់បន្ថយគ្រោះថ្នាក់

### .ការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

តបតាមសំណើរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចាត់តំណាងមន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន ឱ្យរួមដំណើរចុះទៅពិនិត្យទីតាំងដីចំនួន ២០ ហិកតា សម្រាប់សាងសង់មជ្ឈមណ្ឌលជាតិ ព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលមានទីតាំងនៅភូមិត្រពាំងមូល ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាថ្ងៃទី១០/៣/២០១១ ។

តបតាមការអញ្ជើញរបស់ការិយាល័យត្រួតពិនិត្យគ្រឿងញៀននិងឧក្រិដ្ឋកម្មវៀតណាម គណៈប្រតិភូជាន់ខ្ពស់អន្តរក្រសួង ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាសមាជិក បានដឹកនាំប្រតិភូចំនួន ២០រូប ទៅធ្វើទស្សនកិច្ចសិក្សាអំពីការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅទីក្រុងហូជីមិញ កាលពីថ្ងៃទី១៤-១៨ខែមីនាឆ្នាំ២០១១ ។ តាមរយៈដំណើរទស្សនកិច្ចនេះ ទទួលបាននូវលទ្ធផល និងបទពិសោធន៍មួយចំនួនដូចខាងក្រោម :

-ភាគីវៀតណាមបានសន្យាថានឹងជំរុញការអនុវត្តន៍គម្រោងការសាងសង់មជ្ឈមណ្ឌលជាតិព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន តាមរយៈការដាក់បញ្ចូលគម្រោងសាងសង់នេះ ទៅក្នុងគម្រោងនៃកិច្ចសហប្រតិបត្តិការទ្វេភាគីរបស់រដ្ឋាភិបាលរដ្ឋាភិបាលនៃប្រទេសទាំងពីរ (កម្ពុជា-វៀតណាម) ។

-នៅប្រទេសវៀតណាម ការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ត្រូវបានរៀបចំតាមរយៈមជ្ឈមណ្ឌលរបស់រដ្ឋ មជ្ឈមណ្ឌលរបស់ឯកជន មន្ទីរពេទ្យ និងការព្យាបាលតាមសហគមន៍ ។ តាមរយៈបទពិសោធន៍នេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងរៀបចំអនុក្រឹត្យស្តីពីការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន សម្រាប់យកទៅអនុវត្តកម្មវិធីព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅក្នុងមជ្ឈមណ្ឌលរដ្ឋ ឯកជន និងសហគមន៍ ស្របតាមនិយាមជាតិ-អន្តរជាតិ និងច្បាប់ជាតិដែលមានជាធរមាន ។

ពាក់ព័ន្ធនឹងការងារព្យាបាល នៅក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលនិងដកពិសោធន៍លើការអនុវត្តន៍ផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១០ របស់ខេត្តបន្ទាយមានជ័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អជបគញ បានផ្តល់នូវអនុសាសន៍ណែនាំ ដូចតទៅ :

- ខេត្តបន្ទាយមានជ័យ ត្រូវពិនិត្យលទ្ធភាពក្នុងការពង្រីកសេវាថែទាំនិងព្យាបាលអ្នកស្ថិតក្រោមឥទ្ធិពលគ្រឿងញៀន ចំពោះស្រុក/ក្រុង គោលដៅ ដែលមានអ្នកស្ថិតក្រោមឥទ្ធិពលគ្រឿងញៀនច្រើន ដោយសហការជាមួយក្រសួងសុខាភិបាលក្នុងការ រៀបចំផែនការមួយឱ្យបានជាក់លាក់ ។
- ខេត្តបន្ទាយមានជ័យ ត្រូវបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយអង្គការជាដៃគូ ដែលកំពុងធ្វើសកម្មភាពថែទាំនិងព្យាបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយបំផុសឱ្យអង្គការទាំងនោះ ចូលរួមអនុវត្តយន្តការថែទាំនិងព្យាបាលនៅតាម សហគមន៍ឱ្យមានដំណើរការល្អ ។ ដោយឡែក អាជ្ញាធរដែនដី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន

និងយុវនីតិសម្បទា ត្រូវបំផុសដល់ក្រុមគ្រួសារអ្នកស្ថិតនៅក្រោមឥទ្ធិពលគ្រឿងញៀន ឱ្យភ្ញាក់រលឹកបញ្ជូនកូនចៅ និងបំផុសសាមីខ្លួនដែល កំពុងស្ថិតក្រោមឥទ្ធិពលគ្រឿងញៀន ឱ្យស្ម័គ្រចិត្តចូលខ្លួនមកទទួលយកការថែទាំនិងព្យាបាលផ្តាច់សារធាតុញៀន ។

- ខេត្តបន្ទាយមានជ័យ ត្រូវខិតខំអំពាវនាវចំពោះអង្គការដៃគូដែលកំពុងធ្វើសកម្មភាពថែទាំព្យាបាល និងសមាហរណកម្ម ដើម្បីជួយបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញនៅនឹងកន្លែងរបស់អង្គការ ហើយចំពោះមុខ ខេត្តបន្ទាយមានជ័យត្រូវសិក្សា និងរៀបចំយន្តការសមាហរណកម្មយូរអង្វែង សម្រាប់អ្នកជាសះស្បើយពីគ្រឿងញៀន ។
- ខេត្តដទៃទៀត ត្រូវពិនិត្យលទ្ធភាពក្នុងការផ្តល់សេវាថែទាំនិងព្យាបាល នៅតាមមន្ទីរពេទ្យបង្អែករបស់ខេត្ត ឬមណ្ឌលសុខភាពរបស់ស្រុកគោលដៅដែលមានប៉ះពាល់គ្រឿងញៀនច្រើន ។
- ក្រសួងអប់រំយុវជននិងកីឡា ត្រូវយកសាលារៀននៅខេត្តបន្ទាយមានជ័យ ទៅសរសេរជាបទពិសោធន៍ "សាលារៀនពណ៌បៃតង គ្មានគ្រឿងញៀន" សំខាន់អំពីយន្តការក្នុងការគ្រប់គ្រង ការផ្សព្វផ្សាយអប់រំ ដើម្បីរៀបចំចងក្រងជាសៀវភៅ ហើយផ្ញើទៅគ្រប់សាលារៀន ។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវពិនិត្យលទ្ធភាពក្នុងការពង្រីកធនធានមនុស្ស ដូចជា គ្រូបណ្តុះបណ្តាលវិជ្ជាជីវៈ អ្នកគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នហើយត្រូវអំពាវនាវចំពោះអ្នកស្ថិតក្រោមឥទ្ធិពលគ្រឿងញៀន ឱ្យគេភ្ញាក់រលឹកចូលមកព្យាបាល និងគ្រួសារអ្នកស្ថិតក្រោមឥទ្ធិពលគ្រឿងញៀន ដើម្បីគេជំរុញកូនចៅឱ្យចូលខ្លួនមកទទួលយកការថែទាំព្យាបាលផ្តាច់ជាតិញៀន ជាមួយនេះ ត្រូវជួសជុលជុំវិញជម្រកឱ្យបានសមរម្យ ។ ចំពោះក្មេងអនាថា ដែលត្រូវការបណ្តុះបណ្តាលយូរអង្វែង ត្រូវចិញ្ចឹមគាត់នៅក្នុងមណ្ឌល ឬកន្លែងណាដែលនៅជិតមណ្ឌល ដើម្បីងាយស្រួលឃ្លាំមើលសកម្មភាពរបស់ពួកគាត់ ។
- ក្រសួងសុខាភិបាល ត្រូវពិនិត្យលទ្ធភាព ក្នុងការពង្រីកមណ្ឌលសុខភាពសហគមន៍នៅខេត្តបន្ទាយមានជ័យ ហើយត្រូវជួយបណ្តុះបណ្តាលធនធានមនុស្សពាក់ព័ន្ធនឹងការងារព្យាបាលនេះ ។

**.ការកាត់បន្ថយគ្រោះថ្នាក់**

ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយគ្រោះថ្នាក់ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បាន :

-ផ្តល់បណ្ណ័សម្គាល់ខ្លួន សម្រាប់ បុគ្គលិក និង មិត្តអប់រំមិត្ត ចំនួន១៦រូប នៃមណ្ឌលសំចតសាខាមានជ័យ ខណ្ឌមានជ័យ សម្រាប់ការអនុវត្តន៍កម្មវិធីម្ជុល/ស៊ីរ៉ាំង នៅក្នុងរាជធានីភ្នំពេញ ។

-ចូលរួមនៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយ និងការពង្រឹងការអនុវត្តន៍លិខិតជូនដំណឹងលេខ ៦៦ ស.ជ.ណ ចុះថ្ងៃទី១៤ខែតុលា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល នៅសណ្ឋាគារសាន់វ៉េ កាលពីថ្ងៃទី២៨ កុម្ភៈ ឆ្នាំ២០១១ ដែលមានការអញ្ជើញចូលរួមពីអភិបាលរងរាជធានីភ្នំពេញ, អាជ្ញាធរខណ្ឌ, តំណាងក្រសួង-ស្ថាប័ន, អង្គការសង្គមស៊ីវិល អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងម្ចាស់គ្រឹះស្ថានបំរើសេវាកម្សាន្តសប្បាយនៅក្នុងខណ្ឌចំនួន៩នៃរាជធានីភ្នំពេញ សរុបចំនួនជាង ៣០០នាក់ ។ គោលបំណងសំខាន់គឺ សំដៅធ្វើយ៉ាងណាជំរុញនិងលើកកម្ពស់ឱ្យមានការប្រើប្រាស់ស្រោមអនាម័យ ឱ្យបាន១០០%ចំពោះអ្នកមានដៃគូស្នេហាខាងក្រៅ ។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក៏បានផ្សព្វផ្សាយសេចក្តីសម្រេច

របស់ខ្លួនស្តីពី "ការពង្រឹងការគ្រប់គ្រងបុគ្គលិកបម្រើការងារតាមគ្រឹះស្ថានកម្សាន្តសប្បាយ តាមរយៈកម្មវិធីដៃគូសហគមន៍សំរាប់ប្រជាជនប្រឈមមុខខ្ពស់ក្នុងការទប់ស្កាត់រលកទី២នៃការរាលដាលមេរោគអេដស៍/ជម្ងឺអេដស៍" ដែលក្នុងប្រការ៣នៃសេចក្តីសំរេចនេះចែងថា "ម្ចាស់គ្រឹះស្ថានកម្សាន្តសប្បាយទាំងអស់ត្រូវផ្តល់ការគាំទ្រដល់ការបង្ការទប់ស្កាត់ និងការប្រើប្រាស់គ្រឿងញៀន ដែលជាកត្តាជំរុញដល់ការរាលដាលជំងឺអេដស៍" ។

-ចូលរួមផ្តល់បទឧទ្ទេសនាមដល់សិក្ខាកាមជានិស្សិត នៃសាកលវិទ្យាល័យកម្ពុជាអន្តរជាតិ ចំនួន ៤២ នាក់ នៅក្នុងសិក្ខាសាលាស្តីពី ការចរាចរគ្រឿងញៀន និងមេរោគអេដស៍ កាលពីថ្ងៃទី១៨ខែមីនាឆ្នាំ២០១១ ។

**ដោយឡែក :**

-ខេត្តកំពង់ចាមបានរៀបចំក្រុមការងារមួយ ដើម្បីធ្វើការសិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយផែនការប៉ាន់ប្រមាណចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅទូទាំងខេត្ត ដោយបានធ្វើការកោះប្រជុំមន្ត្រីបង្គោលតាមបណ្តាស្រុក/ក្រុង អំពីគោលការណ៍នៃការធ្វើការប៉ាន់ប្រមាណចំនួនអ្នកប្រើប្រាស់គ្រឿងញៀន, ការចាត់តាំងចុះធ្វើការផ្សព្វផ្សាយដល់មន្ត្រីនៅមូលដ្ឋានផ្ទាល់ និងដំឡើងបញ្ជីមាតិកាដើម្បីធ្វើការគ្រប់គ្រង ។

-ខេត្តមណ្ឌលគិរីបានរៀបចំបង្កើត លេខាធិការដ្ឋានត្រួតពិនិត្យគ្រឿងញៀន ថ្នាក់ក្រុង/ស្រុក និងក្រុមពិគ្រោះយោបល់ថ្នាក់ឃុំ/សង្កាត់ ។

**៤.ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តកិច្ចសហការជាមួយអង្គការជាដៃគូ ដើម្បីពង្រឹងសមត្ថភាពការងារអនុវត្តដូចតទៅ :

-បានស្នើសុំឱ្យក្រសួងសុខាភិបាល ដើម្បីនាំចូលគំរូសំណាកសារធាតុញៀនដែលរឹបអូសបាន សារធាតុគីមីផ្សំគ្រឿងញៀន និងសារធាតុញៀនគំរូ របស់អង្គការUNODC ដើម្បីយកមកអនុវត្តការវិភាគរកភាពសុទ្ធនៃសារធាតុញៀន និង សារធាតុគីមីផ្សំគ្រឿងញៀន ។

-បានស្នើសុំទៅក្រសួងយុត្តិធម៌ ឱ្យបន្តការទទួលស្គាល់មន្ត្រីជំនាញ ចំនួន៣រូប របស់អគ្គលេខាធិការដ្ឋាន អជបគញ ក្នុងការធ្វើកោសល្យវិច័យគ្រឿងញៀន សារធាតុញៀន និង សារធាតុគីមីផ្សំគ្រឿងញៀន ។

-បានសហការជាមួយអង្គភាពត្រួតពិនិត្យគ្រឿងញៀនរបស់សហព័ន្ធរុស្ស៊ី រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តគ្រឿងញៀន រួមមាន មន្ត្រីនៃអគ្គនាយកដ្ឋានគយ-រដ្ឋាករ នាយនគរបាលជាតិ កងរាជអាវុធហត្ថ អគ្គនាយកដ្ឋានកាំកុងត្រូល និងមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន អជបគញ សរុបចំនួន ៧៣ រូប នាថ្ងៃទី២២-២៤ ខែមីនា ឆ្នាំ២០១១ នៅអគ្គលេខាធិការដ្ឋាន អជបគញ ។

-បានចាត់តាំងមន្ត្រីជំនាញ របស់អគ្គលេខាធិការដ្ឋាន អជបគញ ចំនួន ៣ រូប ចុះទៅសិក្សាស្រាវជ្រាវនិងប្រមូលព័ត៌មានដែលពាក់ពន្ធ័នឹងការគ្រប់គ្រង ការចរាចរ ការប្រើប្រាស់សារធាតុគីមីផ្សំ នៅខេត្តស្វាយរៀង កាលពីថ្ងៃទី០៦-១៦ ខែមីនា ឆ្នាំ២០១១ ។

-អគ្គលេខាធិការដ្ឋាន អជបគញ តាមការស្នើសុំរបស់នគរបាលសហព័ន្ធអូស្ត្រាលី បានផ្តល់សំណាកគ្រឿងញៀនហេរ៉ូអ៊ីនរបស់សំណុំរឿង PPP1084 និង PPP1089 ឱ្យទៅនគរបាលសហព័ន្ធអូស្ត្រាលី ដើម្បីធ្វើកោសល្យវិច័យប្រៀបធៀបជា

មួយសំណាកដែលចាប់នៅប្រទេសអូស្ត្រាលី ។

-មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អជបគញ បានទទួលម៉ាស៊ីន និងសម្ភារៈបរិក្ខារមន្ទីរពិសោធន៍គ្រឿងញៀន មួយសម្រាប់ពីការិយាល័យអគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១ ដើម្បីបំពេញបន្ថែមនូវកង្វះខាតសម្ភារៈសម្រាប់ការវិភាគគ្រឿងញៀន ។

-អគ្គលេខាធិការដ្ឋាន អជបគញ បានដឹកនាំក្រុមការងារអន្តរក្រសួង រួមមាន តំណាងអង្គការFHI, កម្មវិធីHAARP/AusAIDS, លេខាធិការដ្ឋានអេដស៍ក្រសួងមហាផ្ទៃ, អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍, បណ្ឌិត្យសភានគរបាលជាតិ, អង្គការ KHANA, ក្រសួងសុខាភិបាល និងមន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន អជបគញ សរុបចំនួន ១៥ រូប ដើម្បីពិនិត្យនិងកែសម្រួលឯកសារសម្រាប់កម្មវិធីបណ្ដុះបណ្ដាលមន្ត្រីអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និងកាត់បន្ថយគ្រោះថ្នាក់បណ្ដាលពីការប្រើបំពានគ្រឿងញៀន កាលពីថ្ងៃទី២១-២២ខែមីនា ឆ្នាំ២០១១ ។

**៥.កិច្ចសហប្រតិបត្តិការអន្តរជាតិ**

ដើម្បីចូលរួមចំណែកក្នុងយន្តការត្រួតពិនិត្យគ្រឿងញៀន ទ្វេភាគី ពហុភាគី ជាមួយបណ្ដាប្រទេសនៅក្នុងអនុតំបន់ តំបន់ និង អន្តរជាតិ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបាន :

១-ស្នើសុំទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីចាត់តាំងឯកឧត្តមឯកអគ្គរាជទូត ឬតំណាងស្ថានទូតកម្ពុជាប្រចាំនៅទីក្រុងវីយ៉ែន ដើម្បីចូលរួមក្នុងសម័យប្រជុំលើកទី៥៤នៃគណៈកម្មការគ្រឿងញៀន(Fifty-Fourth Session of the Commission on Narcotic Drugs) នាថ្ងៃទី២២-២៤ខែមីនាឆ្នាំ២០១១ នៅទីក្រុងវីយ៉ែន ប្រទេសអូទ្រីស ។

២-ជួបពិភាក្សាការងារជាមួយលោក Olivier Lemet តំណាងអង្គការUNODC ប្រចាំនៅកម្ពុជា នៅអគ្គលេខាធិការដ្ឋាន អជបគញ កាលពីថ្ងៃទី២៨ខែកុម្ភៈឆ្នាំ២០១១ ។ ភាគីទាំងពីរបានបង្ហាញពីឆន្ទៈនិងការប្ដេជ្ញាចិត្តដូចខាងក្រោម :

ក- បន្តការខិតខំសម្របសម្រួលធ្វើឱ្យមាន ការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្មប្រចាំនៅកម្ពុជាមួយ ដែលមិនមែនជាការិយាល័យគម្រោងដូចសព្វថ្ងៃ ។

ខ- ជំរុញការអនុវត្តន៍គម្រោង ការព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍ ដើម្បីជួយដោះបន្ទុកមណ្ឌលបណ្ដោះអាសន្នសព្វថ្ងៃ ។

គ- បង្ហាញពីឆន្ទៈរបស់ភាគីទាំងពីរ ចំពោះបណ្ដាប្រទេសអ្នកផ្ដល់ជំនួយ ដើម្បីកៀងគរថវិកាសម្រាប់ការអនុវត្តគម្រោងឱ្យទទួលបាននូវប្រសិទ្ធភាពខ្ពស់ ។

ឃ- អង្គការUNODC គ្រោងនឹងបង្កើតគម្រោងស្ដីពីការពង្រឹងសមត្ថភាពរបស់អគ្គលេខាធិការដ្ឋាន អជបគញ សំដៅពង្រឹងសមត្ថភាពមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន អជបគញ, ពង្រឹងសមត្ថភាពត្រួតពិនិត្យគ្រឿងញៀននៅយន្តការថ្នាក់ក្រោមជាតិ, ការជួយពង្រឹងប្រព័ន្ធច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

ដោយឡែក ថ្ងៃទី១៥ខែមីនាឆ្នាំ២០១១ តាមរយៈកិច្ចពិភាក្សាការងាររវាងអគ្គលេខាធិការដ្ឋាន ជាមួយអង្គការ UNODC ប្រចាំនៅទីក្រុងវីយ៉ែន ប្រទេសអូទ្រីស លោកស្រី សូតានី មន្ត្រីទទួលបន្ទុកបញ្ហាគ្រឿង

ញៀន និងជំងឺអេដស៍ បានបង្ហាញពីភាពជោគជ័យក្នុងការអនុវត្តន៍គំរោងកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀន នៅតាមសហគមន៍ នៅខេត្តបន្ទាយមានជ័យ ។ ការងារនេះUNODCនឹងបន្តស្វែងរកថវិកាគាំទ្រពីមូលនិធិសកល ជុំទី១១ ដើម្បីធ្វើឱ្យការអនុវត្តន៍កម្មវិធីមាននិរន្តរភាព ។

៣-បានចាត់មន្ត្រីជំនាញ ទៅចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការប្រឹក្សាយោបល់គម្រោងស្តីពី "ភាពជាដៃគូនៃមន្ត្រីអនុវត្តច្បាប់ក្នុងតំបន់ប្រឆាំងទៅនឹងឧក្រិដ្ឋកម្មឆ្លងដែន"(PATROL- Project Advisory Committee) កាលពីថ្ងៃទី២៤-២៥ ខែកុម្ភៈឆ្នាំ២០១១ នៅសណ្ឋាគារ ឡឺរ៉ូយ៉ាល់ ដែលមានសមាសភាពពាក់ព័ន្ធចូលរួម ចំនួន ១៤ រូប ។ កិច្ចប្រជុំនេះបានឯកភាពគ្នាដូចខាងក្រោម :

-គណៈកម្មការប្រឹក្សាយោបល់ (PAC) ត្រូវដឹកនាំដោយប្រធានមួយរូប ដែលជាអគ្គលេខាធិការ នៃ អជបគញ ។

-ការិយាល័យរបស់ PAC ត្រូវមានទីតាំងនៅក្នុង អគ្គលេខាធិការដ្ឋាន អជបគញ ។

-PAC មានតួនាទីធ្វើជាសេនាធិការជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការដឹកនាំបញ្ហាអនុវត្តគម្រោង តាមរយៈការកសាងផែនការប្រចាំឆ្នាំ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពសំដៅបង្ក្រាបនិងទប់ស្កាត់បទល្មើសគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែននានា នៅតាមបណ្តោយព្រំដែនប្រទេស ។

-PAC ត្រូវមានមធ្យោបាយ និងសម្ភារៈចាំបាច់មួយចំនួន សំរាប់កិច្ចដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន ដែលសម្ភារៈទាំងនោះនឹងត្រូវស្នើសុំឱ្យអង្គការUNODC ជាអ្នកជួយគាំទ្រ ។

៤-ថ្ងៃទី២៧ខែកុម្ភៈ ដល់ ថ្ងៃទី០៣ខែមីនាឆ្នាំ២០១១ មន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រោមគម្រោងPATROL បានសហការជាមួយUNODCអនុតំបន់ ចុះទៅពិនិត្យស្ថានភាពជាក់ស្តែងនៅច្រកទ្វារអន្តរជាតិ"ភ្នំដិន" និងច្រក"កំពង់អំពិល"ក្នុងស្រុកបុរីជលសារ ដែលជាច្រកទ្វេភាគីផ្លូវទឹករបស់ខេត្តតាកែវ និងនៅថ្ងៃទី០១-០៣ខែមីនាឆ្នាំ២០១១ បានបន្តចុះទៅពិនិត្យស្ថានភាពជាក់ស្តែងនៅច្រកទ្វារអន្តរជាតិ"ត្រពាំងផ្លុង" ក្នុងខេត្តកំពង់ចាម ដើម្បីពិចារណាក្នុងការបង្កើតការិយាល័យទំនាក់ទំនងព្រំដែន(BLO) ។

៥-អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជូនកំណត់ហេតុនៃកិច្ចប្រជុំលើកទី១០ រវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនកម្ពុជា និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន អេដស៍ និង ពេស្យាចារ នៃសាធារណរដ្ឋ-សង្គមនិយមវៀតណាម និង គម្រោងស្នើសុំជំនួយសាងសង់មជ្ឈមណ្ឌលជាតិ ព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីលើកគម្រោងសហប្រតិបត្តិការអនាគតសំរាប់ត្រៀមប្រជុំ គណៈកម្មការចម្រុះកម្ពុជា-វៀតណាម លើកទី១២ នៅខែមេសាឆ្នាំ២០១១ ។

៦-យោងតាមស្មារតីប្រជុំទ្វេភាគី កម្ពុជា-ថៃ លើកទី៥ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន កាលពីថ្ងៃទី២០-២៣ខែធ្នូឆ្នាំ២០១០នៅខេត្តត្រាត ភាគីថៃបានផ្តល់ឈ្មោះ និងលេខទូរស័ព្ទអ្នកសម្របសម្រួលតាមព្រំដែនពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀនមកកម្ពុជា ហើយភាគីកម្ពុជាក៏កំពុងរៀបចំបញ្ជីឈ្មោះ និង លេខទូរស័ព្ទមន្ត្រីសម្របសម្រួលតាមព្រំដែនពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀនរបស់កម្ពុជាទៅភាគីថៃផងដែរ ។

**_-នីតិកម្ម_**

ថ្ងៃទី០៩ និងថ្ងៃទី១៦ខែមីនាឆ្នាំ២០១១ ក្រុមការងារតាក់តែងច្បាប់របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បាន

បន្តការប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

***.ការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន***

ដើម្បីជំរុញការអនុវត្តន៍យុទ្ធសាស្ត្រខាងលើ កាន់តែមានប្រសិទ្ធភាព នៅក្នុងឱកាសនៃកិច្ចប្រជុំ បូកសរុបលទ្ធផលនិងដកពិសោធន៍ លើការអនុវត្តន៍ផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១០ របស់ខេត្តបន្ទាយមានជ័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានផ្តល់នូវអនុសាសន៍ណែនាំដូចតទៅ :

- ខេត្តបន្ទាយមានជ័យ ត្រូវបន្តពង្រឹងយន្តការនិងការដឹកនាំអនុវត្តផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀន ឱ្យមាននិរន្តរភាពតាមខ្លឹមសារយុទ្ធសាស្ត្រពហុវិស័យទាំង៥ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ហើយត្រូវពង្រីកយន្តការនេះឱ្យបានទៅដល់ ឃុំ សង្កាត់ ភូមិ ជាពិសេស ឃុំ សង្កាត់ ភូមិ ដែលជាកន្លែងកើតមានការផលិត ការជួញដូរ ចែកចាយ និង ការប្រើប្រាស់គ្រឿងញៀនច្រើន ដើម្បីចូលរួមចំណែកអនុវត្តនូវ គោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។
- ខេត្តបន្ទាយមានជ័យ ត្រូវរៀបចំប្រជុំដកពិសោធន៍ការអនុវត្តន៍ផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀន នៅស្រុកព្រះនេត្រព្រះ ដោយអញ្ជើញស្រុកទាំងអស់មកស្តាប់បទពិសោធន៍ល្អ ក្នុងការធ្វើឱ្យ ភូមិ ឃុំ និង សាលារៀន ក្នុងស្រុកព្រះនេត្រព្រះ គ្មានបញ្ហាគ្រឿងញៀន ។
- ខេត្តបន្ទាយមានជ័យនិងខេត្តដទៃទៀត ត្រូវបន្តការធ្វើបច្ចុប្បន្នភាពទិន្នន័យព័ត៌មានគ្រឿងញៀន តាមគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ដោយមានក្រុមវាយតម្លៃចុះទៅដល់កន្លែងទាំងឡាយណា ដែលមិនទាន់ច្បាស់លាស់ឱ្យបានកាន់តែសុក្រឹតថែមទៀត ។ ចំពោះឃុំណាដែលនៅមានភូមិដែលមានបញ្ហាគ្រឿងញៀនចាប់ពី៤ភូមិឡើងទៅ ត្រូវធ្វើការអង្កេត និងវាយតម្លៃឡើងវិញ ជាពិសេស នៅតាមសាលារៀន ។
- ខេត្តបន្ទាយមានជ័យ ត្រូវសហការជាមួយអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីចងក្រងចំណុចដកបទពិសោធន៍ការអនុវត្តន៍ផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀននេះ ទៅជាឯកសារផ្សព្វផ្សាយ ហើយខេត្តត្រូវមានការដកពិសោធន៍ផ្ទៃក្នុងបន្ថែមទៀត នៅក្នុងអនុគណៈកម្មការទាំង៤នៃគណៈកម្មការអនុវត្តផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀនខេត្ត ។
- ត្រូវចលនាឱ្យមានការចូលរួមពីក្រុមយុវជនស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា និង ក្រុមកាយឫទ្ធិ ដើម្បីជួយលើការងារមិត្តអប់រំមិត្ត ។
- ចំពោះខេត្តដទៃ ត្រូវធ្វើយ៉ាងណាឱ្យយន្តការនៃការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងគ្រឿងញៀន មានដំណើរការល្អ ។

## III. ការសន្និដ្ឋាន និង វាយតម្លៃ

នៅក្នុងខែមីនានេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តយុទ្ធសាស្ត្រពហុវិស័យទាំង៥ ទទួលបានលទ្ធផលល្អប្រសើរ ។ ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ ពីបញ្ហាគ្រឿងញៀន និងមេរោគអេដស៍/ជំងឺអេដស៍ យើងបានផ្តល់នូវឯកសារអប់រំផ្សព្វផ្សាយមួយចំនួនដល់បណ្ណាល័យនៃតាមគ្រឹះស្ថានសិក្សារបស់រដ្ឋ និង ឯកជន សម្រាប់បម្រើឱ្យការសិក្សា

ស្រាវជ្រាវរបស់សាស្ត្រាចារ្យ សិស្ស និស្សិត និងសម្រាប់ជាមូលដ្ឋានក្នុងការផ្សព្វផ្សាយអប់រំ សំដៅឈានទៅបណ្តុះបណ្តាលក្រុមជនបង្គោល មិត្តអប់រំមិត្ត ទាំងនៅក្នុងសាលារៀននិងនៅក្រៅសាលារៀន ។ ប៉ុន្តែយើងនៅជួបការលំបាក ដោយសារយើងនៅមាន ការខ្វះខាតឯកសារនានា សម្រាប់បម្រើឱ្យការងារផ្សព្វផ្សាយអប់រំ ជាហេតុធ្វើឱ្យនៅតាមចំណុចគោលដៅ និងក្រុមជនដែលងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់មួយចំនួន នៅមិនទាន់ទទួលបានចំណេះដឹងអំពីបញ្ហាគ្រឿងញៀន/អេដស៍នៅឡើយ ។ ជាមួយនេះ មន្ត្រីអនុវត្តច្បាប់គ្រប់សមាសភាព គ្រប់លំដាប់ថ្នាក់ បានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀន ធ្វើឱ្យទទួលបានលទ្ធផលខ្ពស់ បើប្រៀបធៀបនឹងខែកុម្ភៈកន្លងទៅ ។ ប៉ុន្តែចំណុចខ្សោយមួយចំនួនក្នុងការអនុវត្តនីតិវិធានការនេះ ពីបញ្ហាថវិកាចំណាយ និងមធ្យោបាយរបស់សមត្ថកិច្ចនៅមានកម្រិត ។ យើងបានយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពដល់មន្ត្រីអនុវត្តច្បាប់ ដូចជាការបណ្តុះបណ្តាលអំពីជំនាញស៊ើបអង្កេត នីតិវិធីតុលាការ ជាដើម ។ ប៉ុន្តែការបណ្តុះបណ្តាលនេះ មិនទាន់បានទៅដល់មន្ត្រីអនុវត្តច្បាប់នៅគ្រប់គោលដៅប្រឈមនៅឡើយ ។ ដោយឡែក ការងារព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន គឺយើងបាននិងកំពុងពង្រឹងសមត្ថភាពក្នុងការផ្តល់សេវានៅតាមមណ្ឌលបណ្តោះអាសន្ន ព្រមទាំងបានដំណើរការដកពិសោធន៍កម្មវិធីព្យាបាលតាមសហគមន៍ នៅខេត្តបន្ទាយមានជ័យ ។ ប៉ុន្តែយើងនៅប្រឈមមុខចំពោះការកើនឡើងនូវចំនួនអ្នកប្រើគ្រឿងញៀន ដែលសមត្ថកិច្ចកំពុងធ្វើយុទ្ធនាការបង្ក្រាបនិងប្រមូលផ្តុំ យកមកដាក់នៅក្នុងមណ្ឌល តែយើងពុំមានលទ្ធភាពទទួលពួកគេ ។ យើងបានខិតខំប្រឹងប្រែងក្នុង ការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិ ទ្វេភាគី ពហុភាគី បានច្រើនជាមួយបណ្តាអង្គការនិងប្រទេសជាដៃគូអភិវឌ្ឍន៍ ដែលនេះ ជាចំណុចគុណសម្បត្តិរបស់យើង ។ ប៉ុន្តែ យើងនៅមិនទាន់ខិតខំឱ្យអស់ពីលទ្ធភាពដើម្បីទាញយកផលប្រយោជន៍ពីគម្រោងទាំងនោះនៅឡើយ ។

## IV. ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែមេសា ឆ្នាំ២០១១

ដូចដែលបានធ្វើការសន្និដ្ឋាននិងវាយតម្លៃអំពីសភាពការណ៍គ្រឿងញៀន និងចំណុចប្រឈមក្នុងការអនុវត្តន៍យុទ្ធសាស្ត្រពហុវិស័យទាំង៥ ខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានដាក់ចេញនូវទិសដៅសម្រាប់អនុវត្តបន្តដូចខាងក្រោម :

១. បន្តកិច្ចសហការ សម្របសម្រួលជាមួយក្រសួងជាសមាជិក អជបគញ និង ក្រសួង-ស្ថាប័នពាក់ព័ន្ធនានា គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ក្នុងការងារផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីគ្រោះថ្នាក់នៃគ្រឿងញៀន និងការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ តាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋនិងឯកជន ។

២. បន្តកិច្ចសហការជាមួយក្រសួងទេសចរណ៍ ជម្រុញការរៀបចំផលិត Sticker សម្រាប់ផ្សព្វផ្សាយពីការងារគ្រឿង អេដស៍ អំពើជួញដូរភេទ អំពើជួញដូរអាវុធជាតិផ្ទុះ ដើម្បីធ្វើការផ្សព្វផ្សាយអប់រំ បង្ការទប់ស្កាត់ បញ្ហាទាំងអស់នេះ នៅតាមគោលដៅប្រឈមនានា និងក្រុមជនដែលងាយប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ ។

៣. ត្រៀមរៀបចំសិក្ខាសាលាថ្នាក់ជាតិលើកទី១ ស្តីពីកម្មវិធីកាត់បន្ថយគ្រោះថ្នាក់នៅកម្ពុជា ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៧-២៩ ខែមេសា ឆ្នាំ២០១១ នៅខេត្តសៀមរាប ។

៤. ត្រៀមរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១០ នៅខេត្តជាប់ព្រំដែននៃប្រទេសឡាវ នាថ្ងៃទី៦-៧ ខែមេសា ឆ្នាំ២០១១ ។

៥. បន្តការចុះសិក្សាស្រាវជ្រាវ ប្រមែប្រមូលទិន្នន័យព័ត៌មានពាក់ពន្ធ័នឹងការគ្រប់គ្រង ការចរាចរ និងការប្រើប្រាស់

សារធាតុគីមីផ្សំ នៅខេត្តស្វាយរៀង ។

៦. បន្តកិច្ចសហប្រតិបត្តិការរៀបចំផែនការសកម្មភាពគម្រោង កម្ពុជា-កូរ៉េ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៧. សម្របសម្រួលជាមួយអង្គការUNODC ដើម្បីបង្កើតការិយាល័យ PAC នៅអគ្គលេខាធិការដ្ឋាន អជបគញ ដោយមានការបំពាក់នូវសម្ភារៈរបស់ការិយាល័យនេះ ដោយអង្គការUNODC ។

៨. សហការសម្របសម្រួលជាមួយអង្គការUNODC ដើម្បីជំរុញការបង្កើតការិយាល័យទំនាក់ទំនងព្រំដែន(BLO) ថ្មីពីរកន្លែង នៅច្រកទ្វារអន្តរជាតិ ត្រពាំងផ្លុង និង ភ្នំដិន ដែលបំពាក់សម្ភារៈដោយអង្គការUNODC ។

៩. រៀបចំប្រកាស ស្តីពីសមាសភាព BLO-PATROL ថ្មី ចំនួន ១៤កន្លែង តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

១០. ត្រៀមបញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន ០១រូប ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាអំពីការធ្វើជំនួញសារធាតុដែលប៉ះ-ពាល់ដល់បរិស្ថាន នាថ្ងៃទី៤-៥ ខែមេសា ឆ្នាំ២០១១ នៅទីក្រុងបាងកក ។

ដើម្បីអនុវត្តបានសម្រេចទិសដៅត្រួតពិនិត្យគ្រឿងញៀនខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននឹងបន្តជំរុញការងារមួយចំនួនដូចខាងក្រោម :

-ការរៀបចំយន្តការបង្កើត សាលារៀនពណ៌បៃតងគំរូគ្មានគ្រឿងញៀន ។

-ការរៀបចំផែនការជាតិ៥ឆ្នាំ( ១០១១-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-ការត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១០ និងទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១ ។

-បន្តកិច្ចសហការជាមួយក្រសួងផែនការ ជំរុញការរៀបចំប្រព័ន្ធទិន្នន័យព័ត៌មានគ្រឿងញៀនថ្នាក់ជាតិ ។

**អគ្គលេខាធិការ**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អជបគញ

-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

"ដើម្បីជូនជ្រាប"

-ក្រសួង សមាជិក អជបគញ

-ក្រសួងផែនការ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត

-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីមុខការ"

-ឯកសារ

# ការងារផ្សព្វផ្សាយអប់រំ ពីគ្រោះថ្នាក់នៃគ្រឿងញៀន ខែមីនា ឆ្នាំ២០១១

| ឈ្មោះ<br>អង្គភាពសាមី | ឈ្មោះអង្គភាព<br>សហការសំរបសំរួល | ខ្លឹមសារផ្សព្វផ្សាយ គោលដៅ សមាសភាព | ចំនួនអ្នក<br>ចូលរួម |
|---|---|---|---|
| អជបគញ | | -ការផ្តល់កិច្ចសម្ភាសន៍ នៅស្ថានីយទូរទស្សន៍ ស៊ីធីអិន<br>-ការផ្តល់ឯកសារផ្សព្វផ្សាយអប់រំ ដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តកំពង់ចាម<br>-ការផ្តល់ឯកសារផ្សព្វផ្សាយអប់រំ ដល់និស្សិតបញ្ញាសាស្ត្រកម្ពុជា<br>-ការផ្តល់ឯកសារផ្សព្វផ្សាយអប់រំ ដល់មណ្ឌលសង្គ្រោះជនរងគ្រោះដោយគ្រឿងញៀនកម្ពុជា | |
| កំពង់ធំ | | -ច្បាប់ និង ផលប៉ះពាល់នៃគ្រឿងញៀន<br>(ស្រុកប្រាសាទសំបូរ ស្រុកប្រាសាទបល្ល័ង្គ ក្រុងស្ទឹងសែន ១៣៣៣ នាក់). (ក្រុងស្ទឹងសែន ២២ នាក់). (ស្រុកប្រាសាទសំបូរ ប្រាសាទបល្ល័ង្គ បារាយណ៍ ក្រុងស្ទឹងសែន ៥១៧១ នាក់) | ៦.៥២៦ នាក់ |
| កំពង់ចាម | | -ច្បាប់ និង ផលប៉ះពាល់នៃគ្រឿងញៀន<br>(វរៈព្រំដែនលេខ ៦១៧ ចំនួន ៣០ នាក់) | ៣០ នាក់ |
| ស្វាយរៀង | | -ប្រជុំផ្សព្វផ្សាយផែនការយុទ្ធនាការប្រឆាំងគ្រឿងញៀន<br>(ស្នងការដ្ឋាននគរបាលខេត្តៈ នគរបាល ៨៥ នាក់) | ៨៥ នាក់ |
| រតនគីរី | | -ផលប៉ះពាល់នៃគ្រឿងញៀន<br>(វើនសៃៈ ២០០ នាក់). | ២០០ នាក់ |
| ប៉ៃលិន | សមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ | -គ្រោះថ្នាក់នៃគ្រឿងញៀន បញ្ហាអេដស៍ បញ្ហាសុខភាពបន្តពូជ និងកាមរោគ<br>(នារីកន្លែងសេវាកំសាន្តៈ ២៩២ នាក់). (ក្រុងប៉ៃលិន ៦៥៤ នាក់) | ៩៤៦ នាក់ |
| កំពង់ឆ្នាំង | | -ផលប៉ះពាល់នៃគ្រឿងញៀន<br>(ស្រុកបរិបូណ៌ ៣៥ នាក់). | ៣៥ នាក់ |
| កែប | | -គ្រោះថ្នាក់នៃគ្រឿងញៀន<br>(ស្រុកដំណាក់ចង្អើរ ប្រជាពលរដ្ឋ ៤៦៧ នាក់). (ក្រុងកែបៈ ៧០ នាក់) | ៥៣៧ នាក់ |
| ព្រះវិហារ | | -ផលប៉ះពាល់នៃគ្រឿងញៀន<br>(ក្រុងព្រះវិហារ ១២២០ នាក់). (ស្រុកឆែប ៨៣០ នាក់). (ស្រុករវៀង ១៤២ នាក់). (ស្រុកជ័យសែន ៥៣២ នាក់). (ក្រុងសែនជ័យៈ ប្រជាពលរដ្ឋ ១០២ នាក់) | ២.៨២៦ នាក់ |
| បាត់ដំបង | | -ផលប៉ះពាល់នៃគ្រឿងញៀន មេរោគអេដស៍ ជម្ងឺអេដស៍<br>(ស្រុកថ្មគោល ៣៦៥៤ នាក់) | ៣.៦៥៤ នាក់ |
| ក្រចេះ | | -គ្រោះថ្នាក់នៃគ្រឿងញៀន និង មេរោគអេដស៍ ជម្ងឺអេដស៍<br>(ក្រុងក្រចេះ និង ស្រុកចិត្របុរី ប្រជាពលរដ្ឋ ១៨១៨ នាក់). (ស្រុកឆ្លូង ១១៥ នាក់). (ក្រុងក្រចេះ ៧៤៦ នាក់). | ២.៦៧៩ នាក់ |
| | | សរុប | **១៧.៥១៨ នាក់** |

# អង្គភាពបង្ក្រាបបទល្មើសគ្រឿងញៀន ក្នុងខែមីនា ឆ្នាំ២០១១

| ល.រ | អង្គភាព | សរុបរួម | | | ផលិតចរាចរជួញដូរចែកចាយ | | | ប្រើប្រាស់គ្រឿងញៀន | | | ចាប់តាមដីកា | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី |
| *1* | ***មន្ទីរប្រឆាំងគ្រឿងញៀន*** | **8** | **28** | **10** | 8 | 28 | 10 | | | | | | |
| *2* | ***ន.ដ្ឋាន សន្តិសុខផ្ទៃក្នុង*** | **0** | **1** | **0** | | | | | | | 0 | 1 | 0 |
| *3* | ***ន.ប ភ្នំពេញ*** | **86** | **217** | **44** | 67 | 186 | 40 | 19 | 31 | 4 | | | |
| *4* | ***ន.ប កណ្តាល*** | **3** | **9** | **2** | 3 | 8 | 1 | | | | 0 | 1 | 1 |
| *5* | ***ន.ប កំពង់ស្ពឺ*** | **1** | **3** | **1** | 1 | 3 | 1 | | | | | | |
| *6* | ***ន.ប កំពង់ចាម*** | **4** | **11** | **1** | 3 | 4 | 1 | 1 | 7 | 0 | | | |
| *7* | ***ន.ប ព្រះសីហនុ*** | **2** | **2** | **2** | 2 | 2 | 2 | | | | | | |
| *8* | ***ន.ប ស្វាយរៀង*** | **1** | **2** | **0** | 1 | 2 | 0 | | | | | | |
| *9* | ***ន.ប ស្ទឹងត្រែង*** | **2** | **5** | **2** | 2 | 4 | 2 | | | | 0 | 1 | 0 |
| *10* | ***ន.ប បាត់ដំបង*** | **0** | **1** | **0** | | | | | | | 0 | 1 | 0 |
| *11* | ***ន.ប កោះកុង*** | **2** | **6** | **3** | 2 | 5 | 3 | | | | 0 | 1 | 0 |
| *12* | ***ន.ប បន្ទាយមានជ័យ*** | **2** | **6** | **2** | 2 | 6 | 2 | | | | | | |
| *13* | **ន.ប ពោធិ៍សាត់** | **1** | **4** | **0** | 1 | 4 | 0 | | | | | | |
| *14* | **ន.ប ប៉ៃលិន** | **1** | **1** | **0** | 1 | 1 | 0 | | | | | | |
| ***សរុប*** | | **113** | **296** | **67** | **93** | 253 | 62 | **20** | 38 | 4 | **0** | 5 | 1 |

## វត្ថុតាងចាប់យក រាយតាមអង្គភាព ក្នុងខែមីនា ឆ្នាំ២០១១

| ល.រ | ឈ្មោះអង្គភាព | វត្ថុតាងចាប់យក | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | *WY* (គ្រាប់) | *ICE* (ក្រាម) | *Heroine* (ក្រាម) | ម្សៅពណ៌ស (ក្រាម) | កញ្ឆាក្រៀម (ក្រាម) | *Ecstasy* (គ្រាប់) | *Pseudo-Ephedrine* | សារធាតុផ្សំ គ្រ.ញ | |
| *1* | **មន្ទីរប្រឆាំងគ្រឿងញៀន** | *89.600* | *6333,03* | | *0,40* | | | | | |
| *3* | **ន.ប ភ្នំពេញ** | *61* | *83,41* | *2,76* | | *277,62* | *4* | *6.210* | *2682 ដប* *5 បាវ* | |
| *4* | **ន.ប កណ្តាល** | | *1,29* | | | | | | | |
| *5* | **ន.ប កំពង់ស្ពឺ** | *1* | | | | | | | | |
| *6* | **ន.ប កំពង់ចាម** | | *0,80* | | | | | | | |
| *7* | **ន.ប ព្រះសីហនុ** | *61* | *8,87* | *1,50* | | | | | | |
| *8* | **ន.ប ស្វាយរៀង** | | *84,80* | | | | | | | |
| *9* | **ន.ប ស្ទឹងត្រែង** | *29.887* | *4,70* | | | | | | | |
| *10* | **ន.ប កោះកុង** | *15* | *0,12* | | | *1 កញ្ចប់* | | | | |
| *11* | **ន.ប បន្ទាយមានជ័យ** | *22* | *67,30* | | | | | | | |
| *12* | **ន.ប ពោធិ៍សាត់** | *121* | | | | | | | | |
| *13* | **ន.ប ប៉ៃលិន** | *16* | | | | | | | | |
| | **សរុប** | ***119.784*** | ***6584,32*** | ***4,26*** | ***0,40*** | ***277,62*** ***1 កញ្ចប់*** | ***4*** | ***6.210*** | ***2682 ដប*** ***5 បាវ*** | |

**វត្ថុតាងផ្សេងៗ ៖** ជញ្ជីងថ្លឹង១, កាំភ្លើងខ្លី១, រថយន្ត១២គ្រឿង, ម៉ូតូ២១គ្រឿង, ទូរសព្ទ័ដៃ៨, កុំព្យូទ័រយួរដៃ២, IPAD ២, ម៉ាស៊ីនថតរូប២ និងឧបករណ៍ប្រើប្រាស់ និងផលិតមួយចំនួន ។

## ទិន្នន័យសារធាតុគីមីផ្សំមានអាជ្ញាប័ណ្ណនាំចូល ប្រចាំខែ មីនា ឆ្នាំ ២០១១

| *ឈ្មោះសារធាតុគីមី* | *ឧស្សាហកម្ម រ៉ែ និងថាមពល* | | | *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* | | | *សរុប* | | |
|---|---|---|---|---|---|---|---|---|---|
| | Kg | L | Amp | Kg | L | Amp | Kg | L | Amp |
| Caustic Soda | 220.400 | | | 133.000 | | | 353.400 | | |
| Sodium Hypo chloride | | | | 10.000 | | | 10.000 | | |
| Sodium Sulfate | | | | 4.605.000 | | | 4.605.000 | | |
| Toluene | 42.006,15 | | | | | | 42.006,15 | | |
| Ethyl Acetate | 29.080 | | | | | | 29.080 | | |
| Methylene Chloride | 24.080 | | | | | | 24.080 | | |
| Hydrochloric Acid | | 270 | | | | | | 270 | |
| Formic Acid | 960 | | | 50.000 | | | 50.960 | | |
| Glacial Acetic Acid | | | | 50.000 | | | 50.000 | | |
| Acetic Acid | 384.120 | | | 33.000 | | | 417.120 | | |
| Acetone | 25.000 | | | | | | 25.000 | | |
| Soda Ash | 385.100 | | | 1.265.000 | | | 1.650.100 | | |
| Methyl Ethyl Ketone | 9.506,15 | | | | | | 9.506,15 | | |
| Sulfuric Acid | 5.140 | | 20 | | | | 5.140 | | 20 |
| Sodium Bicarbonate | | | | 8.000 | | | 8.000 | | |
| Total | **1.120.252,2** | **5.410** | **20** | **6.154.000** | | | **7.274.252,2** | **5.410** | **20** |